

ទិដ្ឋភាពអ្នកដំណើរត្រង់ចំណុចអគ្គនាយកដ្ឋានពន្ធដារកែងមហាវិថីសហព័ន្ធរុស្ស៊ី និងម៉ៅសេងទុង។ ផា លីណា

# JICA សរសើរការរីកចម្រើនការប្រមូលពន្ធរបស់ GDT

Tue, 28 July 2015 សុខ ចាន់

**ភ្នំពេញ:** អគ្គនាយកដ្ឋានពន្ធដារ (GDT) បានធ្វើឲ្យមានការរីកចម្រើនយ៉ាងខ្លាំងទាក់ទងនឹងការពង្រឹងការប្រមូលចំណូលពន្ធតាមរយៈការពង្រឹងសមត្ថភាពស្ថាប័នសវនកម្មពន្ធ និងសេវាអ្នកបង់ពន្ធរយៈពេលជាច្រើនឆ្នាំកន្លងមកក្រោមការគាំទ្ររបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។

សេចក្ដីប្រកាសព័ត៌មានរបស់ JICA ចេញផ្សាយកាលពីថ្ងៃចន្ទ បានឲ្យដឹងថាគម្រោងនេះបានចាប់ផ្ដើមកាលពីខែកញ្ញាឆ្នាំ២០១១ នឹងបញ្ចប់នៅខែកក្កដាឆ្នាំ២០១៥។ គម្រោងនេះមានទិន្នផលសំខាន់ៗពីរដែលកំពុងពង្រឹងសមត្ថភាពស្ថាប័នសវនកម្មពន្ធ និងការកែលម្អសេវាអ្នកបង់ពន្ធ។

សេចក្ដីប្រកាសព័ត៌មាននេះបន្តថា៖«ស្របជាមួយនឹងយុទ្ធសាស្ត្រកាន់តែខ្ពស់ដូចជាការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ និងយុទ្ធសាស្ត្រកៀរគរចំណូល GDT បាននិងកំពុងដើរតួនាទីដ៏សំខាន់នៅក្នុងការរួមចំណែកក្នុងការបង្កើនប្រាក់ចំណូលជាតិតាមរយៈការប្រមូលពន្ធ»។

សេចក្ដីប្រកាសព័ត៌មានលើកឡើងថា ចំណូលពន្ធជាប្រភពហិរញ្ញវត្ថុមួយដ៏សំខាន់ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ និងសេវាសាធារណៈកាន់តែប្រសើរ។

លោក Adachi Itsu ប្រធានតំណាងការិយាល័យ JICA ប្រចាំនៅប្រទេសកម្ពុជាបានប្រាប់ភ្នំពេញប៉ុស្តិ៍ក្នុងអំឡុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរួមរបស់គម្រោង JICA-GDT លើកទី៤ថា បច្ចុប្បន្នប្រជាជនកម្ពុជាមានការយល់ដឹងពីការបង់ពន្ធ ដូច្នេះវាគឺជាការរីកចម្រើនដ៏ល្អមួយនៃការបង្កើនពន្ធ។ សម្រាប់ហេតុផលនេះ JICA បានបញ្ជូនអ្នកជំនាញការជប៉ុនរយៈពេលយូរចំនួនពីររូបដើម្បីជួយដល់ GDT លើការពង្រឹងការអប់រំពន្ធនិងការកែលម្អសេវាពន្ធ។

លោកថ្លែងថា៖ «នៅពេលនេះកម្ពុជាកំពុងក្លាយជាប្រទេសមានប្រាក់ចំណូលកណ្ដាលទាប វាបង្ហាញថា រដ្ឋាភិបាលកម្ពុជាមានថវិកាគ្រប់គ្រាន់បានពីអ្នកបង់ពន្ធជាជាងជំនួយឧបត្ថម្ភ»។

លោកបន្ថែមថា សហគមន៍សេដ្ឋកិច្ចអាស៊ាននឹងត្រូវចាប់ផ្ដើមនៅចុងខែធ្នូឆ្នាំនេះ ហើយកម្ពុជាកំពុងស្ថិតនៅក្នុងដំណើរការនៃការធ្វើសមាហរណកម្មក្នុងតំបន់ ដែលពន្ធគយនឹងត្រូវបានលើកលែងកាន់តែច្រើន ហើយចំណូលបានពីពន្ធគយក្នុងតំបន់នឹងត្រូវធ្លាក់ចុះយ៉ាងខ្លាំងបន្ទាប់ពីការធ្វើសមាហរណកម្មនេះ។

លោកថ្លែងថា៖ «បន្ទាប់ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន វាបង្ហាញថាការប្រមូលពន្ធជាតិអាចកាន់តែមានសារៈសំខាន់ក្នុងការរក្សាទំហំដូចគ្នានៃថវិកាជាតិ»។

លោក គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានកោតសរសើរ និងថ្លែងអំណរគុណដល់ JICA សម្រាប់ការគាំទ្រដល់ GDT លើគម្រោងលើកមុន៣ ដែលបាននិងកំពុងអនុវត្តចាប់តាំងពីឆ្នាំ២០០៤ មក។ ជាលទ្ធផល គម្រោង៣ ដែលគាំទ្រពី JICA ទទួលបានផ្លែផ្កា និងការពង្រីកចំណេះដឹងរបស់មន្ត្រីពន្ធដារស្ដីពីពន្ធ គណនេយ្យ សវនកម្មពន្ធ និងផ្សេងៗទៀត។

លោកថ្លែងថា៖ «GDT នឹងអនុវត្តការបណ្ដុះបណ្ដាលបន្ថែមទៀតដល់មន្ត្រី និងបុគ្គលិកពន្ធដារ ដើម្បីលើកកម្ពស់ការប្រមូលពន្ធ ហើយវាគឺជាផ្នែកមួយនៃកាតព្វកិច្ចរបស់យើងដើម្បីធ្វើបន្តនៅពេលក្រោយទៀត»។

លោកស្រី ចន្ទី អ្នកវិភាគសេដ្ឋកិច្ចថ្លែងថា ស្ថិតក្រោមការគាំទ្រពី JICA ប្រទេសកម្ពុជានឹងកាត់បន្ថយរាល់ការបាត់បង់ថវិកាបានពីការប្រមូលពន្ធ។

លោកបន្ថែមថា ប្រសិទ្ធភាពរបស់ប្រព័ន្ធប្រមូលពន្ធស្ថិតក្រោមការគាំទ្រផ្នែកបច្ចេកទេសរបស់ JICA នឹងមិនចូលជាធរមានភ្លាមៗនោះទេ។

លោកបញ្ជាក់ថា៖ «ជាទូទៅ ប្រសិនបើយើងប្រៀបធៀបប្រព័ន្ធប្រមូលពន្ធនៅក្នុងប្រទេសកម្ពុជាជាមួយប្រទេសថៃ សិង្ហបុរី និងម៉ាឡេស៊ី យើងនៅខ្សោយនៅឡើយ។ ដូច្នេះយើងត្រូវតែពង្រឹងប្រព័ន្ធការប្រមូលពន្ធនេះ»។ លោកបានស្វាគមន៍ដល់ការគាំទ្រយ៉ាងខ្លាំងក្លារបស់ JICA លើ GDT ថាគឺជាការល្អប្រសើរមួយ ហើយនឹងកាន់តែមានប្រសិទ្ធភាពនៅក្នុងការប្រមូលពន្ធនៅប្រទេសកម្ពុជា។

យោងតាមទិន្នន័យចេញផ្សាយពី GDT ការប្រមូលពន្ធគ្រប់ប្រភេទពីអគ្គនាយកដ្ឋានពន្ធដារចាប់ពីឆ្នាំ ២០១២ កើនឡើងរហូតដល់ ៧៤០,៥៣ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៣ បានកើនឡើងដល់ ៩០១,២២ លានដុល្លារ បន្ទាប់មកនៅឆ្នាំ ២០១៤ បានកើនឡើងជិតដល់ ៩៩៤ លានដុល្លារ និងកើនឡើងដល់ ៧០៧ លានដុល្លារ នៅក្នុងរយៈពេល ៦ខែដំបូងឆ្នាំ២០១៥៕ LA